ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៤ ប្រកត

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

នៅព្រឹកថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។
២-សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។
៣-សេចក្តីព្រាងច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
៤-បញ្ហាផ្សេងៗ៖

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ៖

- ៤.១.សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ រវាងព្រះរាជាណាចក្រកម្ពុជានិងម៉ាឡេស៊ី។
- ៤.២.សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋកូរ៉ែ។
- ៤.៣.សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងបើនស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩។

ក្រោយពីបានស្តាប់របាយការណ៍និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

១-សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (Asia Pacific Group on Money Laundering - APG) នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤។ ការចូលជាសមាជិកនេះ តម្រូវឱ្យកម្ពុជាអនុវត្តតាមស្តង់ដាអន្តរជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធមហាប្រល័យ របស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force - FATF) និងត្រូវមានក្របខ័ណ្ឌគតិយុត្តក៏ដូចជាយន្តការអនុវត្តសម្រាប់ប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងការរីកសាយភាយអាវុធមហាប្រល័យ។

សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាក្នុងការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ដើម្បីបំពេញនូវចំណុចខ្វះខាតជាយុទ្ធសាស្ត្រមួយចំនួនទាក់ទងនឹងមូលដ្ឋានគតិយុត្តនិងវិធានការដើម្បីអនុវត្តសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិស្តីពីការដាក់ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅចំពោះហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ បន្ថែមពីលើនេះ សេចក្តីព្រាងច្បាប់នេះនឹងធានាការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយកំណត់អំពីវិធានការបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

២-សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

បន្ទាប់ពីបានក្លាយជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (Asia Pacific Group on Money Laundering - APG) កម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានរៀបចំនូវក្របខ័ណ្ឌគតិយុត្តដោយបានដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ និងបានបង្កើតយន្តការអនុវត្តច្បាប់ដូចជា គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាដើម។

សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីឆ្លើយតបនឹងកង្វះខាតមូលដ្ឋានគតិយុត្តបន្ថែមពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក៏ដូចជាហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ លក្ខខណ្ឌនៃផែនការសកម្មភាពទាំង១៩ចំណុចរបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force - FATF) តម្រូវឱ្យកម្ពុជាធ្វើវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយបន្ថែមខ្លឹមសារសំខាន់ៗ រួមមាន៖ ១-ការកំណត់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃពាក្យបច្ចេកទេស ២-ការបញ្ជាក់បន្ថែមពីនីតិវិធីនៃវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និង ៣-ការបង្កើនកម្រិតពិន័យជាសាច់ប្រាក់នៅក្នុងទណ្ឌកម្មខាងព្រហ្មទណ្ឌ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំជាច្បាប់ថ្មី ដោយបញ្ចូលគ្នានូវខ្លឹមសារជាគោលនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៣ ព្រមទាំងបញ្ចូលយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣ និងអនុសាសន៍តាមស្តង់ដាឆ្នាំ២០១២របស់ក្រុមការងារហិរញ្ញវត្ថុ(FATF)។

៣-សេចក្តីព្រាងច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

សេចក្តីព្រាងច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាបទដ្ឋានគតិយុត្តដ៏មានសារៈសំខាន់និងចាំបាច់មួយ ដែលកំណត់អំពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជានិងរដ្ឋបរទេស ទាក់ទងនឹងដំណើរការនីតិវិធីនានាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងការបង្កក ការចាប់យក និងការរឹបអូសទ្រព្យ ក្នុងគោលបំណងដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ។ សេចក្តីព្រាងច្បាប់នេះក៏នឹងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣ ផងដែរ។

ការរៀបចំសេចក្តីព្រាងច្បាប់នេះគឺមានភាពចាំបាច់ក្នុងការបង្កើតឱ្យមាននីតិវិធីផ្នែកក្នុងមួយច្បាស់លាស់បំពេញបន្ថែមឱ្យក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាដល់ការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ និងការអនុវត្តសន្ធិសញ្ញានានាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ព្រមទាំងបង្កើតឱ្យមានមូលដ្ឋានគតិយុត្តមួយដែលបម្រើដល់ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយបណ្តាប្រទេសក្នុងតំបន់និងអន្តរជាតិ ដោយឈរលើគោលការណ៍នៃការគោរពអធិបតេយ្យនិងផលប្រយោជន៍គ្នាទៅវិញទៅមក។

៤-បញ្ហាផ្សេងៗ៖

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចបញ្ជូនទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ៖

៤.១.សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ រវាងព្រះរាជាណាចក្រកម្ពុជានិងម៉ាឡេស៊ី។

៤.២.សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋកូរ៉េ។

៤.៣.សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែនស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា៖

១- ការអនុវត្តច្បាប់ចរាចរណ៍មិនត្រូវពន្យារពេលដោយសារតែបញ្ហានៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩នោះទេ ហើយត្រូវតែបន្តធ្វើដោយគ្មានការដកថយ ដោយទន់ភ្លន់ និងដោយម៉ឺងម៉ាត់ ដើម្បីការពារសុខសុវត្ថិភាពនិងអាយុជីវិតរបស់ប្រជាជន។ មន្ត្រីនគរបាលចរាចរណ៍ត្រូវបន្តរឹតបន្តឹងការផាកពិន័យចំពោះយានយន្តណាដែលបានប្រព្រឹត្តល្មើសនឹងបទល្មើសចំនួន១៦ចំណុច ដោយក្នុងនោះ៧ចំណុចអនុវត្តចំពោះទោចក្រយានយន្តនិងត្រីចក្រយានយន្ត(ម៉ូតូឬរ៉ឺម៉កកង់បី) និង៩ចំណុចចំពោះរថយន្តធុនស្រាលនិងធុនធ្ងន់។

២- លេខាធិការដ្ឋាន និងសមាជិក សមាជិកា នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

ក-មិនអនុញ្ញាតឱ្យចុះដោះស្រាយរាល់ទំនាស់ទាំងឡាយណាដែល **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** បានដោះស្រាយបញ្ចប់ និងមានសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី(សជណ) រួចហើយនោះទេ។

ខ-មិនអនុញ្ញាតឱ្យដោះស្រាយទំនាស់ដីធ្លីដែលកំពុងដំណើរការតាមនីតិវិធីរបស់តុលាការ។

គ-មិនអនុញ្ញាតឱ្យចុះដោះស្រាយរាល់ទំនាស់ទាំងឡាយណា ដែលបានដោះស្រាយបញ្ចប់ដោយស្ថាប័នតុលាការ ដែលមានសាលក្រម ឬសាលដីកាស្ថាពររួចហើយ។

ឃ-លេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ត្រូវពិនិត្យគោលដៅនិងកម្មវត្ថុដែលសមាជិកនិងសមាជិកានៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ បម្រុងចុះទៅដោះស្រាយ ដោយមិនត្រូវចេញលិខិតបេសកកម្មជូនក្នុងករណីដូចបានរៀបរាប់នៅក្នុងចំណុច «ក» «ខ» និងចំណុច «គ» ខាងលើឡើយ។ ទន្ទឹមនេះ ក៏មិនត្រូវបញ្ជូនសំណុំរឿងវិវាទដីធ្លីរវាងបុគ្គលនិងបុគ្គល ជូនមក **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ដើម្បីធ្វើការដោះស្រាយដែរ។

៣- រាជរដ្ឋាភិបាលសម្រេចផ្តល់ការអនុញ្ញាតឱ្យធ្វើការនាំចេញស្រូវ អង្ករ និងត្រី ទៅក្រៅប្រទេសឡើងវិញ ចាប់ពីថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០២០ នេះតទៅ ដូចមុនពេលប្រកាសបិទ ដោយផ្អែកលើគុណភាពស្បៀងសម្រាប់តម្រូវការក្នុងប្រទេស បន្ទាប់ពីត្រូវបានផ្អាកការនាំចេញនាពេលកន្លងមក។

៤- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចុះត្រួតពិនិត្យអនាម័យនៅតាមភោជនីយដ្ឋាន ហើយត្រូវធ្វើការណែនាំប្រសិនបើមានការខ្វះចន្លោះ។ ក្នុងករណីភោជនីយដ្ឋានណាមួយមិនអនុវត្តស្របតាមវិធានអនាម័យរបស់ក្រសួងសុខាភិបាលក្នុងការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ជំងឺកូវីដ-១៩ ត្រូវផ្អាកអាជីវកម្មជាបណ្តោះអាសន្នរហូតមានការរៀបចំកែលម្អអនាម័យឡើងវិញ ទើបអនុញ្ញាតឱ្យបន្តអាជីវកម្មជាថ្មី។

៥- សំណើសុំបើកសាលារៀនឡើងវិញ មិនគួរធ្វើឡើងដោយប្រញាប់ពេកនោះទេ ព្រោះអាចបង្កជាហានិភ័យនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍។

៦- រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តគោលនយោបាយគាំពារសង្គម ដែលរួមមានការបន្តយកចិត្តទុកដាក់ឧបត្ថម្ភចំពោះកម្មការិនីដែលជាស្ត្រីមានផ្ទៃពោះ គ្រួសារដែលមានជីវភាពក្រីក្រ និងបង្កើនមូលធនថវិកា«សាច់ប្រាក់ពលកម្ម» ដើម្បីជួយដល់កម្មករនិយោជិតដែលបានព្យួរការងារកំលុងពេលដែលរោងចក្រសហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរនិងទេសចរណ៍មួយចំនួនបានផ្អាកដំណើរការ ដោយសារឯផលប៉ះពាល់ធ្ងន់ធ្ងរពីបញ្ហាជំងឺកូវីដ-១៩ ស្របតាមការផ្សព្វផ្សាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៧- រាជរដ្ឋាភិបាលសូមថ្លែងការកោតសរសើរចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក រដ្ឋបាលរាជធានី ខេត្តទាំងអស់ ក្រុមគ្រូពេទ្យ និងសាធារណជន ដែលបានខិតខំចាត់វិធានការការពារនិងរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ការរីករាលជំងឺកូវីដ-១៩នៅកម្ពុជា។

៨- រាជរដ្ឋាភិបាលសូមក្រាបថ្វាយបង្គំអរព្រះគុណជាអនេក ថ្វាយព្រះករុណា **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវព្រះរាជទ្រព្យដល់រាជរដ្ឋាភិបាលកម្ពុជា និងសូមថ្លែងអំណរគុណចំពោះសប្បុរសជននានាដែលបានចូលរួមឧបត្ថម្ភថវិកា ដើម្បីគាំទ្រដល់ការធ្វើសកម្មភាពប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅកម្ពុជា។

៩- រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធទូទាំងប្រទេស ដែលបានចូលរួមជាវិភាគទាននូវប្រាក់បៀវត្សរ៍និងថវិកាផ្ទាល់ខ្លួន ជូនដល់មូលនិធិប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ដែលបច្ចុប្បន្នកើនឡើងរហូតដល់ជាង ៧៣ ០០០នាក់ ក្នុងទំហំទឹកប្រាក់ជាង ៤០ពាន់លានរៀល។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១០និង៣៥នាទី។

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០